**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**<u>ព័ត៌មានពិស្តារអំពីការដាក់ឯកសារ</u>**

**សំណុំរឿងលេខ៖** ០០៤/០៧-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៦២)

ភាគីដាក់ឯកសារ៖ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គបុរេជំនុំជម្រះ

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 22-Aug-2019, 15:45
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គបុរេជំនុំជម្រះ៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

**សំណើបន្ទាន់របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រដើម្បីដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤**

---

**<u>ដាក់ដោយ៖</u>**

**សហមេធាវីតំណាង**

**ដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី

**<u>ផ្ញើជូន៖</u>**

**ចៅក្រមអង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Olivier BEAUVALLET

ចៅក្រម ន័យ ថុល

ចៅក្រម BAIK Kang Jin

ចៅក្រម ហួត វុទ្ធី

**ចម្លងជូន៖**

| **សហចៅក្រមស៊ើបអង្កេត** | **សហព្រះរាជអាជ្ញា** | **សហមេធាវីការពារក្តី យឹម ទិត្យ** |
|---|---|---|
| យូ ប៊ុនឡេង | ជា លាង | សូ មូស្សេទ្ធី |
| Michael BOHLANDER | Brenda HOLLIS (បម្រុង) | Suzana TOMANOVIĆ |

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

| | |
|---|---|
| ហុង គឹមសួន | Laure DESFORGE |
| គឹម ម៉េងឃី | Isabelle DURAND |
| ឡោ ជុនធី | Emmanuel JACOMY |
| សំ សុគង់ | Martine JACQUIN |
| ស៊ិន សុវ៉ន | Daniel MCLAUGHLIN |
| ទី ស្រីនណា | Lyma NGUYEN |
| វ៉េន ពៅ | Nushin SARKARATI |

## I. សេចក្តីផ្តើម

1. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឱ្យអង្គបុរេជំនុំជម្រះពន្យារពេលវេលាកំណត់ ដោយអនុលោមតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង ដើម្បីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស្តីពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី "ដីកាសម្រេចទទួលយកដើមបណ្តឹងរដ្ឋប្បវេណី" ដែលបានចេញនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩[1]។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏ស្នើសុំដោយគោរពផងដែរឱ្យបង្កើនចំនួនទំព័រ និងអនុញ្ញាតឱ្យដាក់បណ្តឹងឧទ្ធរណ៍តែមួយភាសាសិន ជំទាស់ទៅនឹងសេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤។

2. សំណើសុំពន្យារពេលវេលានេះអាចទទួលយកបាន ដោយសារមានមូលហេតុចាំបាច់មួយចំនួន។ ***ទីមួយ*** ការឆ្លើយតបទៅនឹងការបដិសេធយ៉ាងច្រើនចំពោះដើមបណ្តឹងរដ្ឋប្បវេណី*ដ៏សន្ធឹកសន្ធាប់* នៅក្នុងដីកាសម្រេចទទួលយកដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ កាន់តែក្លាយជាបន្ទុកការងារដ៏ធ្ងន់ធ្ងរថែមទៀត ដោយសារតែមានបុគ្គលិក និងធនធានតិចតួចស្តួចស្តើងសម្រាប់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីតែម្នាក់ ដែលតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលត្រូវបានបដិសេធ ហើយធ្វើឱ្យគាត់មិនអាចឆ្លើយតបឱ្យបានពេញលេញទៅនឹងពាក្យសុំនីមួយៗដែលបានបដិសេធ នៅក្នុងរយៈពេល ១០ថ្ងៃ សម្រាប់ការដាក់បណ្តឹងឧទ្ធរណ៍ឱ្យបានឆាប់រហ័សបានឡើយ។ ***ទីពីរ*** ការពន្យារពេលវេលាសម្រាប់ការដាក់បណ្តឹងឧទ្ធរណ៍នានា ប្រឆាំងនឹងដីកាសម្រេចទទួលយកដើមបណ្តឹងរដ្ឋប្បវេណី កាន់តែមានយុត្តិកម្មបន្ថែមទៀត ពីព្រោះថា ទាំងដីកាសម្រេចទទួលយកដើមបណ្តឹងរដ្ឋប្បវេណី ទាំងឧបសម្ព័ន្ធនានាភ្ជាប់ទៅនឹងដីកាសម្រេចនេះ ព្រមទាំងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៤ ("ដីកាដំណោះស្រាយរបស់ ស.ច.ស.អ")[2] ដែលវិសាលភាពនៃការជំនុំជម្រះ ត្រូវបានកំណត់ និងពិភាក្សាលម្អិតនោះ បានផ្តល់មកឱ្យភាគីទាំងអស់តែជាភាសាអង់គ្លេសប៉ុណ្ណោះ។ ការពុំមានសំណៅជាភាសាខ្មែរនៃដីកាដំណោះស្រាយរបស់ ស.ច.ស.អ ធ្វើឱ្យមេធាវីកម្ពុជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្ថិតក្នុងស្ថានភាពលំបាកយ៉ាងខ្លាំង ទាក់ទងនឹងព័ត៌មានដែលខ្លួនអាចរកបានដើម្បីរៀបចំបណ្តឹងឧទ្ធរណ៍របស់

---

[1] ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស្តីពីការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ឯកសារ **D384** ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ [ចាប់ពីនេះតទៅហៅថា "ដីកាសម្រេចអំពីការទទួលយក"]។

[2] ដីកាដំណោះស្រាយ សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ឯកសារ **D382** ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ [ចាប់ពីនេះតទៅហៅថា "ដីកាដំណោះស្រាយរបស់ ស.ច.ស.អ"]។

ខ្លួនប្រឆាំងនឹងដីកាសម្រេចទទួលយកដើមបណ្តឹងរដ្ឋប្បវេណី។ *ទីបី* សំណើសុំបន្ថែមពេលវេលា និងបង្កើតចំនួនទំព័រប្រហាក់ប្រហែលគ្នានេះ ត្រូវបានអង្គបុរេជំនុំជម្រះអនុញ្ញាតនៅក្នុងសំណុំរឿង ០០៤/២ និងសំណុំរឿង ០០៣ រួចមកហើយ[3]។

3. ការពន្យារពេលវេលាមិនធ្វើឲ្យប៉ះពាល់ដល់ ប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធីទេចំពោះបញ្ហានេះ ពីព្រោះការខ្វែងគំនិតគ្នារវាងការចេញដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិ តម្រូវឲ្យអង្គបុរេជំនុំជម្រះ ដោះស្រាយបញ្ហាយុត្តាធិការបុគ្គលរបស់តុលាការនេះមកលើ យឹម ទិត្យ សិន មុននឹងពិចារណាអំពីដីកាសម្រេចទទួលដើមបណ្តឹងរដ្ឋប្បវេណី។ អាស្រ័យហេតុនេះ ការពន្យារបណ្តឹងឧទ្ធរណ៍នានាទាក់ទងនឹងការទទួលដើមបណ្តឹងរដ្ឋប្បវេណី នឹងមិនធ្វើឲ្យប៉ះពាល់ហួសហេតុដល់ផលប្រយោជន៍របស់ភាគីនោះឡើយ។.

4. ដើម្បីជាប្រយោជន៍ដល់ភាពជឿនលឿន មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំការអនុញ្ញាតដាក់សំណើបន្ទាន់ចាំបាច់នេះជាភាសាអង់គ្លេសសិន ឯសំណៅបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

## II. ប្រវត្តិនីតិវិធី

5. នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាដំណោះស្រាយរបស់គាត់ ("ដីកាដំណោះស្រាយរបស់ ស.ច.ស.អ") ដែលចោទប្រកាន់ យឹម ទិត្យ ចំពោះអំពើប្រល័យពូជសាសន៍ទៅលើជនជាតិខ្មែរក្រោម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើមនុស្សឃាត[4]។ នៅថ្ងៃដដែលនេះដែរ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏បានចេញដីកាសម្រេចរបស់គាត់ទទួលយកដើមបណ្តឹងរដ្ឋប្បវេណី ដែលកំណត់ពីបទដ្ឋានសម្រាប់ការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤[5]។ ឧបសម្ព័ន្ធ **ខ** ភ្ជាប់ទៅនឹងដីកាសម្រេចទទួលយកដើមបណ្តឹងរដ្ឋប្បវេណី

---

[3] សេចក្តីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំពន្យាររយៈពេលកំណត់ និងចំនួនទំព័រ សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ៥៨) ឯកសារ **D362/4** ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨។ សេចក្តីសម្រេចលើសំណើបន្ទាន់របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រ ដើម្បីដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៣ សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ឯកសារ **D269/2** ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩។

[4] សំណុំរឿង ០០៣ ដីកាដំណោះស្រាយរបស់ ស.ច.ស.អ។

[5] ដីកាសម្រេចទទួលយកដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៣។

ជាឯកសារសំអាងហេតុដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចមិនទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១១៣ នាក់ក្នុងសំណុំរឿង ០០៤[6]។ ពីដំបូង ឧបសម្ព័ន្ធ ខ ត្រូវបានចេញតែជាភាសាអង់គ្លេសប៉ុណ្ណោះ ហើយសំណៅបកប្រែជាភាសាខ្មែរត្រូវបានដាក់ក្នុងសំណុំរឿងនៅថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៩។ ដីកាដំណោះស្រាយរបស់ ស.ច.ស.អ ដែលសរុបទាំងអស់មានចំនួន ៤៨៧ ទំព័រ ត្រូវបានចេញតែជាភាសាអង់គ្លេសប៉ុណ្ណោះ ដោយពុំទាន់មានការបកប្រែទៅជាភាសាទីពីរនោះឡើយ។ នៅក្នុងដីកាដំណោះស្រាយមួយដាច់ដោយឡែក សហចៅក្រមស៊ើបអង្កេតជាតិ បានបដិសេធបទចោទប្រកាន់ទាំងអស់មកលើ យឹម ទិត្យ ដោយសារតែកង្វះយុត្តាធិការបុគ្គល ("ដីកាដំណោះស្រាយរបស់ ស.ច.ស.ជ") ហើយហេតុនេះ គាត់បានចេញដីកាបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤[7]។ ដីកាសម្រេចទាំងនេះដែលមានកម្រាស់ ៥៧១ ទំព័រ ត្រូវបានចេញតែជាភាសាខ្មែរប៉ុណ្ណោះ ដោយពុំមានការបកប្រែទៅជាភាសាអង់គ្លេស ឬជាភាសាបារាំងនោះទេ។

## III. ច្បាប់ជាធរមាន

6. វិធានផ្ទៃក្នុងចែងថា សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") អាចធ្វើការសម្រេចទៅលើការទទួលយកដើមបណ្តឹងរដ្ឋប្បវេណីនៅទូទាំងដំណាក់កាលស៊ើបសួរ ប៉ុន្តែ ក្រោយពេលចេញដីកាដំណោះស្រាយរួច ស.ច.ស "ត្រូវសម្រេចអំពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលនៅសេសសល់ទាំងអស់ដោយដីកាដោយឡែក"[8]។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិប្តឹងឧទ្ធរណ៍ជំទាស់នឹងសេចក្តីសម្រេចរបស់ ស.ច.ស អំពីការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី ដោយមិនផ្អាកកិច្ចដំណើរការនីតិវិធីទេ[9]។ បណ្តឹងឧទ្ធរណ៍ស្តីពីការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី ស្ថិតក្នុងរបបនៃបណ្តឹងឧទ្ធរណ៍ឆាប់រហ័សរបស់តុលាការ ដែលតម្រូវថា បណ្តឹងឧទ្ធរណ៍ត្រូវដាក់ "ក្នុងរយៈពេល ១០ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងនៃសេចក្តីសម្រេច អំពីភាពអាចទទួលយកបាននូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី"

[6] ឧបសម្ព័ន្ធ ខ៖ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានប្រកាសមិនទទួលយកក្នុងសំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ឯកសារ **D384** ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩។

[7] សហចៅក្រមស៊ើបអង្កេតជាតិ ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ឯកសារ **D381** ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ [ចាប់ពីនេះតទៅហៅថា "ដីកាដំណោះស្រាយរបស់ ស.ច.ស.ជ"]។ សហចៅក្រមស៊ើបអង្កេតជាតិ ដីកាសម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ឯកសារ **D383** ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩។

[8] វិធានផ្ទៃក្នុង អ.វ.ត.ក (វិសោធនកម្មលើកទី ៩) វិធាន ២៣*ស្ទួន*(៣)។

[9] វិធានផ្ទៃក្នុង អ.វ.ត.ក (វិសោធនកម្មលើកទី ៩) វិធាន ២៣*ស្ទួន*(២)-(៣)។

ជាថិរវេលាដែលពុំមានចែងអំពីការពន្យារពេលទេ[10]។ សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារចែងថា ពេលវេលាកំណត់សម្រាប់ការដាក់ឯកសារត្រូវរាប់មួយថ្ងៃ បន្ទាប់ពីថ្ងៃនៃការជូនដំណឹងពីឯកសារ "ជាភាសាខ្មែរ និងភាសាផ្លូវការមួយផ្សេងទៀតរបស់ អ.វ.ត.ក"[11]។

7. សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានការចូលរួមដោយត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព នៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខ អ.វ.ត.ក មានចែងទាំងនៅក្នុងវិធានផ្ទៃក្នុង និងយុត្តិសាស្ត្ររបស់តុលាការនេះ ក៏ដូចជានៅក្នុងគោលការណ៍ទូទៅនៃការចូលរួមរបស់ជនរងគ្រោះ ដែលមានចែងក្នុងច្បាប់អន្តរជាតិ ហើយដែលត្រូវបានទទួលស្គាល់ដោយតុលាការនេះ។ វិធាន ២១ នៃវិធានផ្ទៃក្នុង បង្កើតជាគោលការណ៍សារវ័ន្តដែលណែនាំដល់ដំណើរការរបស់តុលាការ ដែលរួមមាន វិធានផ្ទៃក្នុង នីតិវិធី និងសេចក្តីណែនាំអនុវត្តរបស់ អ.វ.ត.ក "ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ច ដល់ផលប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និង *ជនរងគ្រោះ* ... ដោយគិតដល់*លក្ខណៈពិសេស*របស់ អ.វ.ត.ក"[12]។ អ.ប.ជ បានសម្រេចថា ការបកស្រាយ និងការអនុវត្តច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវធ្វើឡើងឲ្យស្របនឹងលក្ខណៈពិសេសរបស់តុលាការនេះ រួមទាំងបរិបទ គោលបំណង និងកម្មវត្ថុរបស់តុលាការ ដោយរាប់បញ្ចូលទាំងការធានាដល់សិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលបាន "ការចូលរួមប្រកបដោយប្រសិទ្ធភាព" នៅក្នុងកិច្ចដំណើរការនីតិវិធី និងការទទួលបានដំណោះស្រាយ[13]។ វិធាន ២១ នៃវិធានផ្ទៃក្នុង និងមាត្រា ១២(២) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ក៏ធានាដល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី និងតម្រូវផងដែរថា សិទ្ធិរបស់ជនរងគ្រោះ "ត្រូវបានការពារនៅក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី"[14]។

8. នៅក្នុងការសម្រេចទទួលយកសំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំពន្យាររយៈពេលកំណត់ និងបង្កើនចំនួនទំព័រ ដើម្បីដាក់បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចទទួលយកដើមបណ្តឹងរដ្ឋប្បវេណី អង្គបុរេជំនុំជម្រះបានទទួលស្គាល់ថា ក្នុងករណីដែលវិធាននីតិវិធីមានភាពមិនច្បាស់លាស់ ឬបញ្ហាអង្គ

---

[10] វិធានផ្ទៃក្នុង អ.វ.ត.ក (វិសោធនកម្មលើកទី ៩) វិធាន ៧៧*ស្ទួន*(២)។

[11] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក (វិសោធនកម្មលើកទី ៨) មាត្រា ៨.៥ ចុះខែមករា ឆ្នាំ២០០៧។

[12] វិធានផ្ទៃក្នុង អ.វ.ត.ក (វិសោធនកម្មលើកទី ៩) វិធាន ២១(១) (គូសបញ្ជាក់បន្ថែម)។

[13] សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ) ឯកសារ **D404** ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៥៨-៦៥ [ពីនេះតទៅហៅថា "សាលដីកា អ.ប.ជ សម្រេចលើការទទួលយកដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២"]។

[14] វិធានផ្ទៃក្នុង អ.វ.ត.ក (វិសោធនកម្មលើកទី ៩) វិធាន ២១(១)។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ ត្រង់មាត្រា ១២(២)។

ច្បាប់ប៉ះពាល់ដល់សិទ្ធិរបស់ជនរងគ្រោះ នៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក នោះ "គេអាចស្វែងរកការណែនាំនៅក្នុងគោលការណ៍ទូទៅស្តីពីជនរងគ្រោះ ដូចមាននៅក្នុងច្បាប់អន្តរជាតិ" រួមទាំងគោលការណ៍ណែនាំជាមូលដ្ឋានរបស់ អ.ស.ប ស្តីពីជនរងគ្រោះ"[15]។ គោលការណ៍ទាំងនេះអំពាវនាវឱ្យមានយន្តការតាមផ្លូវតុលាការសម្រាប់ដោះស្រាយដល់ជនរងគ្រោះឱ្យបាន "ឆាប់រហ័ស ត្រឹមត្រូវ ... និងអាចអនុវត្តបាន"[16]។ គោលការណ៍ទាំងនេះក៏តម្រូវផងដែរថា ដំណើរការតាមផ្លូវតុលាការ ត្រូវ "ឆ្លើយតប" ទៅជនរងគ្រោះ ដោយ "អនុញ្ញាតឱ្យជនរងគ្រោះបង្ហាញការយល់ឃើញ និងការព្រួយបារម្ភ និងយកទៅពិចារណានៅក្នុងដំណាក់សមស្របនៃកិច្ចដំណើរការនីតិវិធី ក្នុងករណីដែលផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគាត់ត្រូវបានប៉ះពាល់ ដោយមិនឱ្យខូចខាតប្រយោជន៍របស់ជនជាប់ចោទឡើយ"[17]។

## IV. ការពិភាក្សា

9. ដើម្បីជាប្រយោជន៍យុត្តិធម៌ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គួរទទួលបានឱកាសសមរម្យ ត្រឹមត្រូវ អាចអនុវត្តបាន និងប្រកបដោយអត្ថន័យខ្លឹមសារ តាមរយៈមេធាវីរបស់ពួកគាត់ ដើម្បីលើកឡើងពីការយល់ឃើញ និងការព្រួយបារម្ភរបស់ពួកគាត់ ឆ្លើយតបទៅនឹងការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះពាក្យសុំរបស់ពួកគាត់ចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤ ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។

10. នីតិវិធីស្តីពីភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលមានចែងក្នុងវិធាន ២៣*ស្ទួន* ប្រមើលឃើញថា សហចៅក្រមស៊ើបអង្កេតអាចសម្រេចលើពាក្យសុំទាំងអស់នេះជាបន្តបន្ទាប់ នៅទូទាំងអំឡុងពេលនៃការស៊ើបសួរ។

---

[15] សេចក្តីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំពន្យាររយៈពេលកំណត់ និងចំនួនទំព័រ សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ៥៨) ឯកសារ **D362/4** ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៧ *ដកស្រង់*សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ) ឯកសារ **D404/2/4** ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣២។

[16] សេចក្តីប្រកាសស្តីពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌ សម្រាប់ជនរងគ្រោះដោយសារឧក្រិដ្ឋកម្ម និងការរំលោភបំពានអំណាច សេចក្តីសម្រេចរបស់មហាសន្និបាត អ.ស.ប លេខ 40/34 ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ ត្រង់គោលការណ៍ទី១១ [ពីនេះតទៅហៅថា "សេចក្តីប្រកាសរបស់ អ.ស.ប ស្តីពីការរំលោភបំពានអំណាច"]។ *សូមមើលផងដែរ* សេចក្តីប្រកាសស្តីពីគោលការណ៍ជាមូលដ្ឋាន និងការណែនាំអំពីសិទ្ធិទទួលបានដំណោះស្រាយ និងការរៀបចំសម្រាប់ជនរងគ្រោះដោយសារការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ សេចក្តីសម្រេចរបស់មហាសន្និបាត អ.ស.ប លេខ 60/147 ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥ ត្រង់គោលការណ៍ទី១១ [ពីនេះតទៅហៅថា "គោលការណ៍ជាមូលដ្ឋានរបស់ អ.ស.ប ស្តីពីសិទ្ធិទទួលបានឧបាស្រ័យ"]។

[17] សេចក្តីប្រកាសរបស់ អ.ស.ប ស្តីពីការរំលោភបំពានអំណាច ត្រង់គោលការណ៍ទី៦(ក)-(ខ)។

ហេតុដូច្នេះ សេចក្តីសម្រេចស្តីពីការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានប្តឹងឧទ្ធរណ៍ជាបុគ្គល ដោយផ្អែកលើមូលដ្ឋានមួយដែលឆាប់រហ័ស ដូចមានចែងក្នុងវិធាន ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុង។ ប៉ុន្តែ ករណីនៅទីនេះ ដោយសារតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ត្រូវបានសម្រេចនៅក្នុងដីកាដំណោះស្រាយក្នុងពេលតែមួយ នោះវាធ្វើឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ស្ថិតក្នុងស្ថានភាពមួយដែលមិនអាចធ្វើទៅបានក្នុងការចាត់ចែងបណ្តឹងឧទ្ធរណ៍ឱ្យបានឆាប់រហ័សសម្រាប់កូនក្តីដែលមានចំនួនជាងមួយរយនាក់ នៅក្នុងពេលតែមួយបានឡើយ។ សហចៅក្រមស៊ើបអង្កេត អាចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅពេលណាមួយក៏បាន។ នៅក្នុងការអនុញ្ញាតមួយស្រដៀងគ្នានេះដែរ ក្នុងសំណុំរឿង ០០៤/២ និងសំណុំរឿង ០០៣ អង្គបុរេជំនុំជម្រះបានទទួលស្គាល់ថា ការខកខានមិនបានពន្យាររយៈពេលកំណត់ខ្លីដូចមានចែងក្នុងវិធាន ៧៧*ស្ទួន*នៃវិធានផ្ទៃក្នុង នឹងជា "ការរារាំងមិនឱ្យជនរងគ្រោះចូលរួមប្រកបដោយប្រសិទ្ធិភាព ព្រមទាំងរំលោភលើវិធាន ២១ នៃវិធានផ្ទៃក្នុង និងគោលការណ៍អន្តរជាតិស្តីពីការធានានូវផលប្រយោជន៍របស់ជនរងគ្រោះ"[18]។ ដោយសារតែវិសាលភាពធំធេងនៃការបដិសេធនៅក្នុងដីកាសម្រេចទទួលយកដើមបណ្តឹងរដ្ឋប្បវេណី និងដោយសារតែធនធានតិចតួចស្តួចស្តើង ដែលសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីតែម្នាក់ ដែលតំណាងឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំង ១១៣ នាក់ដែលត្រូវបានបដិសេធអាចប្រើប្រាស់បាន សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំបន្ថែមពេលវេលាចំនួន ៣០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីការបកប្រែជាភាសាខ្មែរនៃដីកាដំណោះស្រាយរបស់ ស.ច.ស.អ ដើម្បីដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួនជំទាស់នឹងដីកាសម្រេចទទួលយកដើមបណ្តឹងរដ្ឋប្បវេណី។

11. ដីកាដំណោះស្រាយរបស់ ស.ច.ស.អ លើកឡើង និងរៀបរាប់លម្អិតច្បាស់លាស់អំពីវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលក្នុងនោះ ការសម្រេចលើការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី ទៅក្នុងសំណុំរឿង ០០៤ ត្រូវបានយកមកសំអាង។ លទ្ធភាពរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីការពារប្រកបដោយប្រសិទ្ធភាព នូវសិទ្ធិរបស់កូនក្តីខ្លួនក្នុងការចូលរួមកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០៤ តាមរយៈដំណើរការបណ្តឹងឧទ្ធរណ៍ស្តីពីការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី គឺអាស្រ័យលើការយល់ដឹងច្បាស់លាស់របស់ខ្លួនអំពីវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ហេតុដូច្នេះ នៅពេលចាប់

[18] សេចក្តីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំពន្យាររយៈពេលកំណត់ និងចំនួនទំព័រ សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ៥៨) ឯកសារ **D362/4** ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៩។ សេចក្តីសម្រេចលើសំណើបន្ទាន់របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រ ដើម្បីដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៣ សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ឯកសារ **D269/2** ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩ កថាខណ្ឌ ៣។

ផ្ដើមគិតរាប់រយៈពេលសម្រាប់បណ្ដឹងឧទ្ធរណ៍ស្ដីពីការទទួលយកដើមបណ្ដឹងរដ្ឋប្បវេណី ខណៈដែលមានតែសំណៅជាភាសាអង់គ្លេសនៃដីកាដំណោះស្រាយរបស់ ស.ច.ស.អ សម្រាប់សហមេធាវីកម្ពុជាតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនោះ គឺធ្វើឱ្យរូបគាត់ និងកូនក្ដីរបស់គាត់ខាតប្រយោជន៍យ៉ាងសម្បើមនៅក្នុងកិច្ចដំណើរការនីតិវិធី និងរំលោភលើគោលការណ៍ជាមូលដ្ឋានស្ដីពីភាពត្រឹមត្រូវផ្នែកនីតិវិធីដែលណែនាំដល់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក។ វាជាការពិតហើយដែលថាសហមេធាវីកម្ពុជាតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន ដែលតំណាងឱ្យកូនក្ដីរបស់ខ្លួន ពុំមានសហមេធាវីដែលចេះនិយាយភាសាអង់គ្លេសនោះទេ។ អាស្រ័យហេតុនេះ ដើម្បីរក្សាដល់ភាពត្រឹមត្រូវនៃដំណើរការប្ដឹងឧទ្ធរណ៍ ស្ដីពីការទទួលយកដើមបណ្ដឹងរដ្ឋប្បវេណី និងដើម្បីធានាការពារដល់ផលប្រយោជន៍របស់ជនរងគ្រោះនៅក្នុងដំណើរការនីតិវិធី ពេលវេលាកំណត់សម្រាប់បណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចទទួលយកដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ មិនគួរចាប់ផ្ដើមគិតនោះទេ រហូតទាល់តែសំណៅបកប្រែជាភាសាខ្មែរនៃដីកាដំណោះស្រាយរបស់ ស.ច.ស.អ ត្រូវបានបកប្រែរួចរាល់សិន។

12. ការពន្យារពេលវេលាសម្រាប់ការប្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចទទួលយកដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤ នឹងផ្ដល់ឱកាសកាន់តែទូលំទូលាយដល់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការជួបប្រាស្រ័យទាក់ទងជាមួយកូនក្ដីរបស់ខ្លួនដែលភាគច្រើនរស់នៅតាមទីជនបទដាច់ស្រយាលនៅទូទាំងប្រទេស និងនៅក្រៅប្រទេស។ ការពន្យារពេលវេលានេះ នឹងអនុញ្ញាតឱ្យសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានការប្រឹក្សាយោបល់ប្រកបដោយប្រសិទ្ធភាពជាមួយនឹងកូនក្ដីរបស់ខ្លួន ដើម្បីដាក់ការជំទាស់តវ៉ាមួយដែលមានមូលដ្ឋានត្រឹមត្រូវ ទៅនឹងការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះការមិនទទួលយកនេះ។ ក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីដ៏សំខាន់នេះ ពេលដែលសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមឱ្យបានពេញលេញ ស្ថិតក្នុងភាពស្រពិចស្រពិលបែបនេះ ការប្រឹក្សាយោបល់ពិតជាមានសារៈសំខាន់ណាស់ ប្រសិនបើតុលាការពិតជាបំពេញកាតព្វកិច្ចរបស់ខ្លួនដើម្បីការពារផលប្រយោជន៍របស់ជនរងគ្រោះ និងគោរពសិទ្ធិរបស់ពួកគាត់ក្នុងការទទួលបានការចូលរួមប្រកបដោយប្រសិទ្ធភាព តាមរយៈដំណើរការបណ្ដឹងឧទ្ធរណ៍ដែលអាចទទួលបានមែននោះ។

13. លើសពីនេះទៀត សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ អនុញ្ញាតឱ្យសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានពេលវេលាបន្ថែម នឹងមិនធ្វើឱ្យអន្តរាយដល់សិទ្ធិរបស់ភាគីដទៃទៀតនោះទេ ហើយក៏មិនប៉ះពាល់ដល់ប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤ នោះដែរ។ ជាបញ្ហាបឋម ការខ្វែងយោបល់គ្នាផ្នែកយុត្តាធិការរវាងសហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិ និងផលប៉ះពាល់របស់វាប្រសិនបើមាន ទៅលើឋានៈរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង

០០៤ ត្រូវតែដោះស្រាយដោយអង្គបុរេជំនុំជម្រះ មុននឹងដោះស្រាយលើការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ដោយសារថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅតែមានសិទ្ធិក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី រហូតទាល់តែមានសេចក្តីសម្រេចស្ថាពរលើការសម្រេចទទួលយកពួកគាត់នោះ វាមានហេតុផល ឬភាពចាំបាច់តិចតួចដែលអង្គបុរេជំនុំជម្រះត្រូវសម្រេចលើបណ្តឹងឧទ្ធរណ៍ ស្តីពីការទទួលយកដើមបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលនេះ។ ដូចគ្នានេះដែរ មេធាវីការពារក្តីបានដាក់សំណើសុំពន្យារពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនជំទាស់នឹងដីកាដំណោះស្រាយទាំងពីរ ដោយស្នើសុំពេលវេលាចំនួន ១៤ ថ្ងៃបន្ថែមទៀត គិតចាប់ពីថ្ងៃជូនដំណឹងអំពីការបកប្រែដីកាដំណោះស្រាយទាំងពីរ[19]។

14. នៅ អ.វ.ត.ក ជនរងគ្រោះមានសិទ្ធិទទួលបានវិធានការការពារ និងការពិចារណាឲ្យបានពេញលេញទៅតាមគោលការណ៍ច្បាប់ជាសារវ័ន្ត វិធានសម្រាប់តុលាការ និងគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ។ នៅក្នុងបញ្ហានីតិវិធី ដូចជា ការអនុញ្ញាតផ្តល់ពេលវេលាក្នុងការដាក់បណ្តឹងឧទ្ធរណ៍ ចៅក្រមនៃអង្គបុរេជំនុំជម្រះបានកត់សម្គាល់ពី "ភាពចាំបាច់ជាសារវ័ន្ត ... ដើម្បីធានាចំពោះការគោរពនីតិវិធីដែលបានបង្កើតឡើងដើម្បីទទួលបាន "ភាពយុត្តិធម៌ទៅតាមនីតិវិធី" មិនមែនដើម្បី "ភាពយុត្តិធម៌ទៅតាមលទ្ធផលដែលខ្លួនចង់បាននោះទេ""[20]។ ការអនុញ្ញាតទៅតាមសំណើសុំបន្ថែមពេលវេលា អង្គបុរេជំនុំជម្រះនឹងធានាថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទទួលបានយុត្តិធម៌ទៅតាមនីតិវិធី ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់ពួកគាត់ស្តីពីការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី។

## V. សំណើ

15. យោងតាមមូលហេតុដូចបានលើកឡើងខាងលើ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដោយក្តីគោរពដល់អង្គបុរេជំនុំជម្រះមេត្តា៖

ក. **ពន្យារ**កាលបរិច្ឆេទកំណត់សម្រាប់ដាក់បណ្តឹងឧទ្ធរណ៍ជំទាស់នឹងសេចក្តីសម្រេចស្តីពីការទទួលយកដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ រយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីការបកប្រែទៅជាភាសាខ្មែរនៃដីកាដំណោះស្រាយរបស់ ស.ច.ស.អ។

---

[19] សំណើរបស់ យឹម ទិត្យ សុំពន្យារពេលនៃការបរិច្ឆេទសម្រាប់ការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ) ឯកសារ **D381/1** ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩។

[20] មតិយោបល់របស់ចៅក្រម Lahuis និងចៅក្រម Downing សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លោក រ៉ូប៊ីត ហាមីល (Robert Hamill) សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ០២) ឯកសារ **D11/2/4/4** ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ ត្រង់កថាខណ្ឌ ១០។

ខ. **បន្ថែម**ចំនួនទំព័រកំណត់សម្រាប់ដាក់បណ្តឹងឧទ្ធរណ៍ ស្តីពីការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី រហូតដល់ ៤៥ ទំព័រ។ និង

គ. **អនុញ្ញាតឲ្យ**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដាក់បណ្តឹងឧទ្ធរណ៍នានារបស់ខ្លួនតែមួយភាសាសិន អាចជាភាសាខ្មែរ ឬភាសាអង់គ្លេសក៏បាន ចំណែកសំណៅបកប្រែនឹងដាក់ជូនតាមក្រោយ។

សូមលោកចៅក្រមមេត្តាទទួលយកសំណើនេះដោយក្តីគោរព។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ | **ជេត វណ្ណលី**<br>មេធាវីកម្ពុជាតំណាង<br>ដើមបណ្តឹងរដ្ឋប្បវេណី | រាជធានីភ្នំពេញ<br>ប្រទេសកម្ពុជា | |